ការធ្វើដំណើរជាមួយកុមារនៅក្នុងឡាន

ច្បាប់ប្រទេសអូស្ត្រាលីតម្រូវថា កុមារទាំងអស់អាយុក្រោម 7 ឆ្នាំត្រូវប្រើកៅអីសុវត្ថិភាពកុមារ ពេលណាធ្វើដំណើរនៅក្នុងឡាន។ ការនេះគឺដើម្បីការពារកុមារពីការរងរបួស ប្រសិនបើគេពាក់ព័ន្ធក្នុងការបុកឡាន។

ប្រភេទនៃកៅអីសុវត្ថិភាពកុមារដែលត្រូវការ គឺផ្អែកទៅលើអាយុ និងទំហំដងខ្លួនរបស់កុមារ។ កៅអីសុវត្ថិភាពកុមារត្រូវមានទំហំត្រឹមត្រូវសម្រាប់កុមារ កែតម្រូវ និងរឹតបណ្តឹងបានសមរម្យ ហើយរៀបចំបានយ៉ាងត្រឹមត្រូវទៅនឹងរថយន្ត។

Khmer

EARLY LEARNING ASSOCIATION AUSTRALIA

កុមារអាយុពី 0–6 ខែ

ត្រូវធ្វើដំណើរក្នុងកៅអីសុវត្ថិភាពកុមារបែរមុខទៅខាងក្រោយ។ កៅអីសុវត្ថិភាពកុមារត្រូវតែបានដាក់នៅលើកៅអីខាងក្រោយ - មិនមែនកៅអីខាងមុខទេ។

កុមារអាយុពី 6 ខែ ទៅ 4 ឆ្នាំ

- អាចធ្វើដំណើរក្នុងកៅអីសុវត្ថិភាពកុមារបែរមុខទៅខាងក្រោយ ឬកៅអីបែរទៅខាងមុខ ដោយមានបន្ទះខ្សែដាក់ពីក្នុង ពីងផ្អែកលើទំហំដងខ្លួនរបស់កុមារ។ កុមារត្រូវធ្វើដំណើរក្នុងកៅអីសុវត្ថិភាពប៉ុណ្ណោះ នៅលើកៅអីខាងក្រោយ - មិនមែនកៅអីខាងមុខទេ។
- ឥឡូវនេះមានកៅអីសុវត្ថិភាពដែលមានខ្សែចងការពារដាក់ពីក្នុង សម្រាប់កុមារអាយុរហូតដល់ទៅ 8 ឆ្នាំ។

កុមារអាយុពី 4 ឆ្នាំ ទៅយ៉ាងតិច 7 ឆ្នាំ



- អាចធ្វើដំណើរក្នុងកៅអីបែរទៅខាងមុខ ឬកៅអីបន្តុប ពីងផ្អែកលើទំហំដងខ្លួនរបស់កុមារ។ កៅអីបន្តុបលើកកំពស់កុមារទៅចំកន្លែងត្រឹមត្រូវ ដើម្បីឲ្យអាចពាក់ខ្សែក្រវាត់បានត្រឹមត្រូវ។
- កុមារអាយុពី 4 - 7 ឆ្នាំអាចធ្វើដំណើរក្នុងកៅអីខាងមុខ (ដោយប្រើកៅអីបន្តុប) ប្រសិនបើកុមារអាយុក្រោម 7 ឆ្នាំប្រើអស់កៅអីខាងក្រោយប៉ុណ្ណោះ។
- កៅអីបន្តុបដែលមានក្បាលបន្ទះខ្សែចងខាងក្រោយ និងខាងលើ វាមានសុវត្ថិភាពជាងប្រភេទកៅអីបន្តុបឯទៀត។
- កុមារគួររក្សាអង្គុយលើកៅអីបន្តុប រហូតទាល់តែគេមានកំពស់ 145 សង្ទីម៉ែត្រ។ ប្រសិនបើផ្លាស់ប្តូរអង្គុយក្នុងកៅអីមនុស្សជំទង់ដែលមានខ្សែក្រវាត់ នោះគេប្រថុយនឹងគ្រោះថ្នាក់រងរបួស ប្រសិនបើគេពាក់ព័ន្ធក្នុងការបុកឡាន។

ការរៀបចំដាក់កៅអីសុវត្ថិភាព

ត្រូវធ្វើតាមការណែនាំរបស់អ្នកផលិតជាដរាប ពេលណារៀបចំដាក់កៅអីសុវត្ថិភាពកុមារ ឬកៅអីបន្តុបទៅក្នុងរថយន្តរបស់លោកអ្នក។

សម្រាប់កុមារអាយុក្រោម 4 ឆ្នាំ, ការរៀបចំដាក់កៅអីសុវត្ថិភាព មានន័យថា:

- កៅអីសុវត្ថិភាពត្រូវបានដាក់ជាប់មាំល្អទៅក្នុងឡាន ដោយសិកខ្សែក្រវាត់តាមរន្ធដែលមានសញ្ញាសំគាល់ រួចហើយរឹតបន្តឹងវា។



- ថ្ពក់ក្បាលបន្ទះខ្សែចងខាងលើទៅនឹងឡាន។

- រឹតបន្តឹងបន្ទះខ្សែដើម្បីទប់កុមារក្នុងកៅអីសុវត្ថិភាព។



សម្រាប់កុមារអាយុលើសពី 4 ឆ្នាំ, ធ្វើដំណើរក្នុងកៅអីបន្តុប:

- ប្រសិនបើមានក្បាលបន្ទះខ្សែចងខាងលើ ត្រូវថ្ពក់វាទៅនឹងឡាន។
- ត្រូវរឹតបន្តឹងខ្សែក្រវាត់ជុំវិញកុមារ។



ការជ្រើសរើសកៅអីសុវត្ថិភាព

មានតែកៅអីសុវត្ថិភាពកុមារ និងកៅអីបន្តុបដែលបំពេញតាមស្តង់ដាសុវត្ថិភាពប្រទេសអូស្ត្រាលី (AS/NZS 1754) ប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឲ្យប្រើ។ ការនេះមានន័យនេះ កៅអីឡានដែលទិញពីប្រទេសផ្សេងទៀតចូលមកក្នុងប្រទេសអូស្ត្រាលី ពុំបានអនុញ្ញាតឲ្យប្រើប្រាស់ឡើយ។

សូមព្យាយាមជៀសវាងការប្រើកៅអីសុវត្ថិភាពកុមារ ឬកៅអីបន្តុបដែលគេប្រើប្រាស់រួចហើយ ដោយហេតុថាកៅអីទាំងនេះអាចខូចខាត ហើយនឹងពុំមានសុវត្ថិភាពឡើយនឹងប្រើប្រាស់។

មានការជាកពិន័យយ៉ាងច្រើន ហើយអស់ពិន្ទុបណ្ណបើកបរផងដែរ ចំពោះការមិនបានប្រើប្រាស់កៅអីសុវត្ថិភាព។ ការជាកពិន័យទាំងនេះអនុវត្តចំពោះមនុស្សម្នាក់ៗនៅក្នុងឡានដែលមិនបានប្រើប្រាស់កៅអីសុវត្ថិភាពត្រឹមត្រូវ។